**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ១៣៣៣០១ ប្រ.ក

# ប្រកាស
## ស្តីពី
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ
## របស់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញប្រកាសលេខ១៣៣០០ប្រ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- យោងតាមសំណើរបស់អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

## សម្រេច

**ប្រការ១.**

អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌស្ថិតនៅក្រោមឱវាទអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងស្ថិតនៅក្រោមការគ្រប់គ្រងដឹកនាំណែនាំជំនាញរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានសមត្ថកិច្ចថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមជូនប្រជាពលរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌ ។

**ប្រការ២.**

អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មានភារកិច្ច ដូចខាងក្រោម ៖

-អនុវត្តការងាររក្សាសន្តិសុខ សុវត្ថិភាពក្នុងមូលដ្ឋានទទួលខុសត្រូវ

-ការពារអាយុជីវិត សិទ្ធិសេរីភាព ទ្រព្យសម្បត្តិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន

-ការពារសន្តិសុខ សុវត្ថិភាពប្រតិភូជាតិ-អន្តរជាតិ ភ្ញៀវបរទេស និងទេសចរ

-ការពារសម្បត្តិវប្បធម៌បេតិកភណ្ឌជាតិ ទ្រព្យសម្បត្តិសាធារណៈ និងគោលដៅសំខាន់ៗ
-រៀបចំសណ្តាប់ធ្នាប់សាធារណៈ សណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក ទឹក ដែក ក្នុងភូមិសាស្ត្រទទួលខុសត្រូវ
-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើអនិតិជន និតិជន និងអំពើហិង្សាក្នុងគ្រួសារ
-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀនក្នុងភូមិសាស្ត្រទទួលខុសត្រូវ
-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ឧក្រិដ្ឋកម្មមានអង្គការចាត់តាំងបទល្មើសព្រហ្មទណ្ឌ និងបទល្មើសផ្សេងៗទៀតដែលប្រឆាំងសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សង្គម
-កត់ត្រាស្ថិតិអាជីវកម្ម សិប្បកម្ម និងមុខរបរដែលងាយប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាពប្រជាពលរដ្ឋ
-ចាត់វិធានការការពារពិនិត្យកន្លែងកើតហេតុ ប្រមូលវត្ថុតាងបម្រើការងារស៊ើបអង្កេត និងដាក់បន្ទុក
-គ្រប់គ្រងការចុះបញ្ជីស្ថិតិអាវុធ គ្រឿងផ្ទុះ ជាតិងាយឆេះ ជាតិពុល អាស៊ីដខ្លាំង ។ល។
-ធ្វើការងារស្រាវជ្រាវ ប្រមូលព័ត៌មាន បង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពបង្កចលាចលសង្គម និងសកម្មភាពភេរវកម្ម
-ចាប់ខ្លួន ឃាត់ខ្លួន និងកសាងសំណុំរឿងបញ្ជូនទៅស្ថាប័នអយ្យការ និងតុលាការតាមនីតិវិធី
-អនុវត្ត និងសហការអនុវត្តសាលដីការ និងដីកានានារបស់ស្ថាប័នអយ្យការ និងតុលាការ
-ធ្វើអន្តរាគមន៍ សង្គ្រោះអាយុជីវិត និងទ្រព្យសម្បត្តិប្រជាពលរដ្ឋពេលមានគ្រោះមហន្តរាយនានាកើតឡើង
-គ្រប់គ្រងការចុះបញ្ជីស្ថិតិប្រជាពលរដ្ឋ និងការងារផ្តល់អត្តសញ្ញាណប័ណ្ណ
-ធ្វើការងារគ្រប់គ្រងជនបរទេសក្នុងភូមិសាស្ត្រទទួលខុសត្រូវ
-ស្រាវជ្រាវរកមនុស្សបាត់ខ្លួន
-គ្រប់គ្រង បញ្ជាដឹកនាំប៉ុស្តិ៍នគរបាលរដ្ឋបាលក្រោមឱវាទ
-រៀបចំបញ្ជីសារពើភ័ណ្ឌ កាន់កាប់ ប្រើប្រាស់ និងថែរក្សាទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាព
-ធ្វើការងាររដ្ឋបាល បុគ្គលិក ភស្តុភារ និងគណនេយ្យរបស់អធិការដ្ឋាន
-ធ្វើរបាយការណ៍បូកសរុប សន្និដ្ឋានវាយតម្លៃអំពីលទ្ធផលការងារ និងទិសដៅបន្តរបស់អធិការដ្ឋានតាមការកំណត់
-បំពេញភារកិច្ចផ្សេងៗទៀត ដែលអភិបាលក្រុង ស្រុក ខណ្ឌ និងស្នងការនគរបាលរាជធានី ខេត្តប្រគល់ឲ្យ។

**ប្រការ៣.-**

អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ដឹកនាំដោយអធិការ០១រូប និងមានអធិការរងមួយចំនួនដឹកនាំផែនការងារ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ជាជំនួយការតាមការចាំបាច់។

**ប្រការ៤.-**

អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

១- ផ្នែកសេនាធិការ
២- ផ្នែកកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល
៣- ផ្នែកសន្តិសុខ
៤- ផ្នែកនគរបាលយុត្តិធម៌
៥- ផ្នែកពិនិត្យវិភាគកន្លែងកើតហេតុ
៦- ផ្នែកប្រឆាំងគ្រឿងញៀន
៧- ផ្នែកសណ្តាប់ធ្នាប់សាធារណៈ
៨- ផ្នែកអត្តសញ្ញាណកម្ម
៩- ផ្នែកគ្រប់គ្រងជនបរទេស (មាននៅក្រុង ស្រុក ខណ្ឌមួយចំនួន)
១០- ផ្នែកការពារ និងអន្តរាគមន៍ (មាននៅរាជធានីភ្នំពេញ និងក្រុងសៀមរាប នៃខេត្តសៀមរាប) ។ ../..

**ប្រការ៥.-**

អំពីតួនាទី និងភារកិច្ចរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។ ដោយឡែក ភារកិច្ច និងរបៀបរបបការងាររបស់ផ្នែកចំណុះអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ។

**ប្រការ៦.-**

រចនាសម្ព័ន្ធរបស់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៧.-**

ផ្នែកនីមួយៗដឹកនាំដោយនាយផ្នែកចំនួន០១រូប និងមាននាយរងផ្នែកចំនួន០២រូប ជាជំនួយការ ។

**ប្រការ៨.-**

ទំនាក់ទំនងការងារ ៖

- រវាងអធិការនគរបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាទំនាក់ទំនងណែនាំអនុវត្តគោលការណ៍ ផែនការរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌពាក់ព័ន្ធការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ
- រវាងអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ជាទំនាក់ទំនងបញ្ជាដឹកនាំការងារជំនាញ
- រវាងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ជាទំនាក់ទំនងគ្រប់គ្រងបញ្ជាដឹកនាំការងារជំនាញ

**ប្រការ៩.-**

ប្រកាសលេខ០៤៣ប្រ.ក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៨ ស្តីពីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធរបស់អធិការដ្ឋាននគរបាលស្រុក-ខណ្ឌ និងការកំណត់ទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ និងជំនួសដោយប្រកាសនេះ ។

**ប្រការ១០.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងអធិការនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល៖</u>

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី*
*-ដូចប្រការ១០*
*-ឯកសារ-កាលប្បវត្តិ*

# អធិការដ្ឋាននគរបាលក្រុង-ស្រុក-ខណ្ឌ

ឧបសម្ព័ន្ធនៃប្រកាសលេខ ១៣៣០១ ប្រ.ក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០១៦
ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ




រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០១៦
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

**បញ្ជាក់ :** -ផ្នែកគ្រប់គ្រងជនបរទេស មានតែនៅអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌមួយចំនួន
-ផ្នែកការពារ និងអន្តរាគមន៍ មានតែនៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងអធិការដ្ឋាននគរបាលក្រុងសៀមរាប ។